ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល. ថ្ងៃទី០៩ខែ 6 ឆ្នាំ ២០14
ក្រឡាបញ្ជី
[redacted]

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ៧៦៥ អ.ក
ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៣
សាលក្រមលេខ: ០៧ (ឆ.ក.ន)
ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤

# គាជំណាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោង ៩ ព្រឹក ដោយមានសមាសភាពដូចតទៅ:

**<u>ចៅក្រមជំនុំជម្រះ</u>**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**<u>តំណាងអយ្យការ</u>**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៧៦៥អក ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៣ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ: កសិករ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្នភូមិក្រូចសើច ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ: [redacted] (រ) មានកូន ០៣នាក់ ទោសពីមុនគ្មាន។

ជាប់ចោទពីបទ៖ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិក្រូចសើច ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]។

Scanned by CamScanner

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៩០៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ០១៨ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ វេលាម៉ោង ១២ និង ៣០នាទីថ្ងៃត្រង់ ស្ថិតនៅភូមិក្រូចសើច ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឈ្មោះ[redacted]នផឹកស្រាស្រវឹង និងបានគំរាមមកលើឈ្មោះ[redacted]ឱ្យដោះចិញ្ចៀនប្រគល់ឱ្យខ្លួន ហើយឈ្មោះ[redacted]បានដោះឱ្យ។ លុះបន្តិចក្រោយមក ឈ្មោះ[redacted]ដែលត្រូវជាឪពុករបស់ឈ្មោះ[redacted]បានទៅសួរនាំឈ្មោះ[redacted] បន្ទាប់មកក៏មានការទាស់ពាក្យសំដីគ្នា ឈ្មោះ [redacted]បានវាយទៅលើឈ្មោះ[redacted]ចំនួន មួយដៃ ត្រូវចំចិញ្ចើមខាងស្តាំរបួស ហើយក៏មានឈ្មោះ[redacted] បានមកដល់ និងចូលឃាត់ តែឈ្មោះ[redacted] មិនស្តាប់ ថែមទាំងបានរត់ឡើងលើផ្ទះទៅយកកណ្តៀវមកវាយលើឈ្មោះ[redacted]បណ្តាលឱ្យរបួសមុតសើរស្បែក និងជាំហើម ទើបសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ១២ថ្ងៃត្រង់ ខ្លួនបានផឹកស្រាសរ អស់កន្លះលីត្រគ្នា២នាក់ បណ្តាលឱ្យស្រវឹងតិចៗ។ លុះដល់ម៉ោងប្រហែល ១ ថ្ងៃត្រង់ ខ្លួនបានឱ្យឈ្មោះ [redacted]អាយុប្រហែល ១០ឆ្នាំជាង ដោះចិញ្ចៀនឱ្យខ្លួន ដែលជាចិញ្ចៀនម្តាយខ្លួនទិញឱ្យវា។ លុះបន្តិចក្រោយមកឈ្មោះ [redacted]ដែលត្រូវជាឪពុករបស់ឈ្មោះ[redacted] បានមកជួបខ្លួនដើម្បីសួរនាំពីដំណើររឿង និងទាមទារចិញ្ចៀនមកវិញ រហូតដល់មានទំនាស់ពាក្យសំដីគ្នា ខ្លួនក៏បានវាយទៅលើឈ្មោះ[redacted] ចំនួនមួយដៃ ចំចិញ្ចើមខាងស្តាំ ពេលនោះឈ្មោះ[redacted] បានមកដល់ និងបានចូលឃាត់។ ខ្លួនមិនបានយកកណ្តៀវកាប់ទៅលើឈ្មោះ[redacted]នោះទេ។ ថ្ងៃនោះខ្លួនមិនដឹងថា ខ្លួនមានកាន់កណ្តៀវ ឬអត់ដែរ ដោយសារតែខ្លួនស្រវឹងខ្លាំងពេក។ ខ្លួនមិនដែលប្រព្រឹត្តបទល្មើសពីមុនមកទេ។ ខ្លួនស្នើសុំដល់តុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង គឺខ្លួនដឹងកំហុសហើយ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានឆ្លើយថា នៅថ្ងៃកើតហេតុនោះ កូនរបស់ខ្លួនឈ្មោះ[redacted] បានប្រាប់ខ្លួនថា ពុក[redacted]ដោះយកចិញ្ចៀនពីដៃទៅបាត់ហើយ។ ភ្លាមនោះខ្លួនក៏ដើរទៅផ្ទះរបស់ឈ្មោះ[redacted]ដើម្បីសួរនាំ ពេលនោះឈ្មោះ [redacted]មានសភាពស្រវឹងស្រាជោគជាំ កំពុងអង្គុយនៅក្រោមផ្ទះ ហើយខ្លួនក៏សួរនាំឈ្មោះ[redacted]ដើម្បីយកចិញ្ចៀនមកវិញ តែឈ្មោះ [redacted]មិនឱ្យ និងថែមទាំងបានដាល់មកលើខ្លួនចំចិញ្ចើមខាងស្តាំបែកចេញឈាមទៀតផង។ រួចខ្លួនបានទៅប្តឹងប៉ូលីស



Scanned by CamScanner

ហើយឈ្មោះ [redacted] ជាប៉ូលិសបានចូលឃាត់ និងលួងលោមឱ្យឈ្មោះ [redacted] ចកណ្តៀវ តែត្រូវឈ្មោះ [redacted] យកខ្នងកណ្តៀវគោះលើខ្នងរបស់ឈ្មោះ [redacted] ថែមទៀតផង។ ថ្ងៃនោះខ្លួនមិនបានស្រវឹងស្រាទេ។ ខ្លួនមិនទាមទារសំណងអ្វីទេ។

-សាក្សីឈ្មោះ [redacted] បានឆ្លើយថា កាលនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ១ ថ្ងៃត្រង់ ខ្លួនបានឃើញប្តីរបស់ខ្លួនឈ្មោះ [redacted] បានសំឡុតក្មួយខ្លួនឈ្មោះ [redacted] ឱ្យដោះចិញ្ចៀនឱ្យគាត់ ឈ្មោះ [redacted] យំរួចដោះចិញ្ចៀនឱ្យ។ បន្តិចក្រោយមកឈ្មោះ [redacted] ដែលត្រូវជាឪពុករបស់ឈ្មោះ [redacted] បានមកដល់ ហើយប្រាប់ឱ្យប្តីខ្លួនឱ្យចិញ្ចៀនមកវិញ ទើបបណ្តាលឱ្យមានទំនាស់ពាក្យសំដី និងបានប្រតាយប្រតប់គ្នា។ ខ្លួនមិនដឹងថានរណាវាយនរណាមុនទេ។ ភ្លាមនោះឈ្មោះ [redacted] បានគរបាលប៉ុស្តិ៍ពុកឫស្សីបានមកដល់ និងចូលឃាត់ តែប្តីរបស់ខ្លួនឈ្មោះ [redacted] បានរត់ឡើងមកលើផ្ទះ និងយកកណ្តៀវមកគោះត្រូវចំខ្នងឈ្មោះ [redacted] បណ្តាលឱ្យរបួសបន្តិច។

-សាក្សីឈ្មោះ [redacted] បានឆ្លើយថា កាលពីថ្ងៃមិនចាំក្នុងខែតុលា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ១២ថ្ងៃត្រង់ ពូខ្លួនឈ្មោះ [redacted] បានមកដោះចញ្ចៀនខ្លួនពីដៃ ហើយបានស្រែកដាក់ខ្លួនថា "ចិញ្ចៀននេះ ជាចិញ្ចៀនរបស់គាត់" រួចខ្លួនបានទៅប្រាប់ឪពុករបស់ខ្លួនថា "[redacted] បានដោះយកចិញ្ចៀនខ្លួន"។ ពេលនោះឪពុកខ្លួនបានដើរទៅផ្ទះរបស់ពូវុទ្ធី និងស្រែកសួរថា "ម៉េចបានឯងដោះចិញ្ចៀនកូនអញ" ហើយពេលនោះក៏បានប្រតាយប្រតប់គ្នាតែម្តង។ បន្ទាប់មកពូវុទ្ធី បានរត់ទៅយកកណ្តៀវ ហើយឪពុករបស់ខ្លួនក៏បានរត់ចេញ។ បន្តិចក្រោយមកឃើញប៉ូលិសមកដល់ ឈ្មោះ [redacted] បានកណ្តៀវគោះលើខ្នងប៉ូលិសបន្តិច។ ប៉ូលិសក៏បានឃាត់ខ្លួនគាត់តែម្តង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោល និងស្តាប់ចម្លើយជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឃើញថាកាលពីថ្ងៃ២៧ ខែតុលា ឆ្នាំ២០១៣ ជនជាប់ចោទពិតជាបានវាយទៅលើឈ្មោះ [redacted] បណ្តាលឱ្យបែកចិញ្ចើម និងយកកណ្តៀវកាប់លើឈ្មោះ [redacted] បណ្តាលឱ្យរបួសប្រាកដមែន។ ហេតុដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ៖ ៩០៩ ដកសពចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ទុកជាបានការដដែល ពីបទ៖ ហិង្សាដោយចេតនា តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

-មេធាវីការពារឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្ញុំបាទសូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ កូនក្តីរបស់ខ្លួនបានឆ្លើយសារភាព និងទទួលស្គាល់នូវកំហុសរបស់ខ្លួនថា ខ្លួនពិតជាបានវាយតប់លើបងឈ្មោះ [redacted] មែន ប៉ុន្តែឈ្មោះ [redacted] ក៏បានវាយមកលើកូនក្តីខ្លួនដែរ។ លើសពីនេះទៅទៀត កូនក្តីខ្លួនមិនមានចេតនាកាប់លើប៉ូលិសទេ គឺគ្រាន់តែយកកណ្តៀវគោះលើខ្នង បើកូនក្តីខ្លួនមាន



Scanned by CamScanner

ចេតនាកាប់លើប៉ូលីស ប្រាដកជារបួសធ្ងន់ធ្ងរហើយ។ ហេតុដូច្នេះខ្លួនស្នើសុំដល់តុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួន, ពិចារណាពីស្ថានសម្រាលទោស និងការព្យួរទោសដល់កូនក្តីខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយថា កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ១២ និង ៣០នាទីថ្ងៃត្រង់ ខ្លួនបានឱ្យឈ្មោ[redacted]ដោះចំពៀនឱ្យខ្លួន និងបានវាយទៅលើល[redacted]ចំនួនមួយដៃចំចិញ្ចើមខាងស្តាំ ពេលនោះឈ្មោះ[redacted] បានមកដល់ និងបានចូលឃាត់ ដែលមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាក្សីឈ្មោះ [redacted]សាក្សីឈ្មោះ[redacted]បានឆ្លើយស្រដៀងគ្នាថា ពួកខ្លួនបានឃើញឈ្មោះ[redacted]វាយលើឈ្មោះ [redacted]ពិតប្រាកដមែន។

២.តាមចម្លើយជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី អាចបញ្ជាក់បានថា កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ ស្ថិតនៅចំណុចភូមិក្រូចសើច ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted]ពិតជាមានចេតនាវាយជនរងគ្រោះបណ្តាលឱ្យរងរបួស ដែលអំពើនេះច្បាប់ចាត់ទុកថាជាបទ ហិង្សាដោយចេតនា បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៣.អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរូបរាងកាយរបស់ជនរងគ្រោះ ហើយជនជាប់ចោទជានីតិជនមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

៤.មានភស្តុតាង និងធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិក្រូចសើច ឃុំពុកឫស្សី ស្រុកខ្សាច់ក



Scanned by CamScanner

ណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៥.ជនជាប់ចោទឈ្មោះ [redacted] បានសហការជាមួយតុលាការ, មានការស្តាយក្រោយចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត, ទើបតែប្រព្រឹត្តបទល្មើសលើកដំបូង, អំពើរបស់ជនជាប់ចោទមិនបង្កនូវលុសនកម្មធ្ងន់ធ្ងរទៅដល់ជនរងគ្រោះ និងមិនដែលប្រព្រឹត្តបទល្មើសពីមុនមក ហេតុដូច្នេះគប្បីតុលាការពិចារណាពីស្ថានសម្រាលទោសដល់ជនជាប់ចោទតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ។

៦.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មិនទាមទារសំណងពីជនជាប់ចោទ ហេតុដូច្នេះ តុលាការនឹងមិនធ្វើការពិចារណាពីសំណងរដ្ឋប្បវេណីទេ។

៧.វត្ថុមាន កណ្តៀវខ្វារផ្លែដែកដងឈើចំនួនមួយ ជាសម្ភារៈប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

**ដូច្នេះសម្រេចសេចក្តី**

១/ផ្តន្ទាទោសឈ្មោះ [redacted] ចាម ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ៧ (ប្រាំពីរ) ខែ ពីបទ៖ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិក្រូចសើច ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

២/រឹបអូសវត្ថុតាងមាន កណ្តៀវខ្វារផ្លែដែកដងឈើចំនួនមួយ ទុកជាសម្បត្តិរដ្ឋ។

សាលាក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]

ឯកសារ

[illegible] ខែកុម្ភៈ [illegible]

[redacted]



Scanned by CamScanner